ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

- សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤០៩
ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
- សាលក្រមលេខៈ ០១ "ញ" / ១១
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
បន្ទាយមានជ័យ,ថ្ងៃទី... ខែកញ្ញា ឆ្នាំ២០២១
ក្រឡាបញ្ជី

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

- បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការទី១ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។
- កាលបរិច្ឆេទបើកសវនាការ ៖ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០។
- កាលបរិច្ឆេទប្រកាសសាលក្រម ៖ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សា
[redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា
- លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

- លោក [redacted] ឋានៈព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

- លោក [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៤០៩ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទៈ

១. ឈ្មោះ [redacted] វិចិត្រ ហៅ អន ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្ននៅភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] អាត់ "រស់" ម្ដាយឈ្មោះ [redacted] ស៊ុន "រស់" នៅលីវ ជាអនីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

*ដីកាបង្គាប់ឱ្យនាំខ្លួនលេខ ១៥៦ ព្រទ.I "ក"/២០ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។*

មានលោកស្រី [redacted] និងលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រ។



Scanned with CamScanner

២. ឈ្មោះ [redacted]ប៉ុនិន ហៅ ជ្រូក ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] រេន "រស់" ម្តាយឈ្មោះ [redacted] សេង "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៧ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

*ដីកាបង្គាប់ឱ្យនាំខ្លួនលេខ ១២៦ ព្រទ.I "ក"/២០ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។*

៣. ឈ្មោះ [redacted] ថៃ ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋាននៅភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ធី "រស់" ម្តាយឈ្មោះ [redacted] សារី "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៩ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

*ដីកាបង្គាប់ឱ្យនាំខ្លួនលេខ ១២៧ ព្រទ.I "ក"/២០ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។*

៤. ឈ្មោះ [redacted] រ៉យ ភេទប្រុស កើតឆ្នាំ២០០០ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] សារ៉េត "រស់" ម្តាយឈ្មោះ [redacted] សារ៉ែ "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

*ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១៣៩ ព្រទ.I "ក"/២០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។*

៥. ឈ្មោះ [redacted] សីហា ហៅ ហា ភេទប្រុស កើតឆ្នាំ២០០០ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្ននៅភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ភិរម្យ "រស់" ម្តាយឈ្មោះ [redacted] រ៉ា "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៩ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

*ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១៣៨ ព្រទ.I "ក"/២០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។*

៦. ឈ្មោះ [redacted] ថោង ហៅ ង៉ា ភេទប្រុស កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៨ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្ននៅភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] រឿ "រស់" ម្តាយឈ្មោះ [redacted] ឈឿត "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៩ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

*ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ ៤១៣៧ ៣ស.ព្រស "ក"/២០ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។*

មានលោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថោង។

*ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាសហចារី)* ប្រព្រឹត្តនៅចំណុចសំណង់កាត់ទឹកស្ទឹង ស្ថិតនៅភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ។៚



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណី

១. ឈ្មោះ [redacted] ហៀ ភេទប្រុស កើតឆ្នាំ១៩៦១ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិដូនឡើក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិដូនឡើក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ហៀង "ស្លាប់" ម្តាយឈ្មោះ [redacted] មុន "រស់" ប្រពន្ធឈ្មោះ [redacted] សាលាវ ជាតិ នីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី២ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

២. ឈ្មោះ [redacted] អុល ភេទប្រុស កើតថ្ងៃទី១២ ខែមករា ឆ្នាំ១៩៦១ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិខ្ពប ឃុំខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិថ្មដប់ ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ ចេង អឿន "ស្លាប់" ម្តាយឈ្មោះ ពត ហម "រស់" ប្រពន្ធឈ្មោះ ធិន លឿង ជានីតិជន កម្រិតវប្បធម៌ (មិនចេះអក្សរ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀ និងឈ្មោះ [redacted] អុល។

## ១. អង្គហេតុចោទប្រកាន់មានដូចតទៅ

កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ០៣រសៀល នៅចំណុចសំណង់កាត់ទឹកស្ទឹង ស្ថិតនៅភូមិដូនឡើក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយជនសង្ស័យចំនួន ០៦នាក់ ១. ឈ្មោះ [redacted] វិចិត្រ ហៅ អន ភេទប្រុស អាយុ ១៧ឆ្នាំ, ២. ឈ្មោះ [redacted] សុនិន ហៅ ជ្រូក ភេទប្រុស អាយុ ១៩ឆ្នាំ, ៣. ឈ្មោះ [redacted] ថៃ ភេទប្រុស អាយុ ១៩ឆ្នាំ, ៤.ឈ្មោះ [redacted] វ៉ៃ ភេទប្រុស អាយុ ១៩ឆ្នាំ, ៥. ឈ្មោះ [redacted] សីហា ហៅ ហា ភេទប្រុស អាយុ ១៩ឆ្នាំ និង ៦. ឈ្មោះ [redacted] ប៉ុង ហៅ ង៉ា ភេទប្រុស អាយុ ២១ឆ្នាំ អ្នកទាំង ០៦នាក់ រស់នៅភូមិចារថ្មី ឃុំគោកបល្ល័ង្គ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បានយកកាំបិតកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ហៀ ភេទប្រុស អាយុ ៥៨ ឆ្នាំ ត្រូវចំបួនកន្លែង ត្រង់ថ្ពាល់ខាងស្តាំ, ស្មារខាងស្តាំ, កំភួនដៃខាងស្តាំ និងកែងដៃខាងឆ្វេង និងឈ្មោះ [redacted] សារ៉ាយ ភេទប្រុស អាយុ ១៩ឆ្នាំ ត្រូវត្រង់ខ្នងចំនួន ០២កាំបិត។ ក្រោយកើតហេតុដើមបណ្តឹងបានមកដាក់ពាក្យបណ្តឹងនៅអធិការនគរបាលស្រុកមង្គលបូរី បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១០៨៥ អ.យ.ខ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។
- **បានឃើញ** ដីកាដំណោះស្រាយលេខ ៥០៦៧ ៣ស.ព្រស "ក"/២០ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។
- **បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ ១២៧៩ ៣ស.ព្រជ "ក"/២០ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

## ២. នាពេលសវនាការ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀ ភេទប្រុស បានឆ្លើយថា នៅកើតហេតុ ថ្ងៃ.ខែ.ឆ្នាំ មិនចាំ កូនប្រុសខ្លួនឈ្មោះ [redacted] សីហា ទូរស័ព្ទប្រាប់ថាមានគេចង់កាប់វានៅសំណង់ នៅភូមិដូនឡើក ខ្លួនក៏ទៅជួបកូនប្រុស និងទៅជួបអ្នកដែលរកកាប់វា ដោយមានគ្នាបីនាក់ ខ្លួន កូនរបស់ខ្លួន និងមិត្តភក្តិកូនខ្លួនម្នាក់ មិនស្គាល់ឈ្មោះ ពេលទៅជួបពួកគេមានគ្នា ៦នាក់ ចំណោមនោះខ្លួនស្គាល់ឈ្មោះហៅក្រៅពីរនាក់ គឺឈ្មោះ [redacted]

និងឈ្មោះ ជ្រូក បន្ទាប់មកខ្លួនបានដើរទៅឈរនិយាយទល់មុខគ្នានឹងឈ្មោះ អន ឯបក្សពួកវា ០៥នាក់ ខ្លះនៅអង្គុយលើម៉ូតូ ខ្លះឈរក្បែរម៉ូតូ នៅចម្ងាយបីម៉ែត្រ នៅពេលនោះខ្លួនក៏សួរថា ម៉េចបានរកកាប់កូនអញ និងយកដៃស្តាំទៅកាន់ស្មាររបស់វា ហើយវាក៏ច្រានខ្លួនចេញ ខ្លួនក៏រុញទៅវាវិញដែរ ពេលនោះខ្លួនបានឃើញឈ្មោះ ជ្រូក ដកកាំបិតតាំងតោចេញពីម៉ូតូ ខ្លួនក៏ចាប់ដកខ្សែក្រវ៉ាត់មកកាន់នៅដៃ ស្រាប់តែឈ្មោះ ជ្រូក និងក្មេងប្រុសពាក់អាវដៃវែង ពណ៌ខៀវ គ្នាវាម្នាក់ទៀត មានកាន់ដាវម្នាក់មួយ បានរត់មកកាប់ខ្លួនព្រមគ្នា ពេលពួកវាកាប់ខ្លួនត្រូវមួយកាំបិត ខ្លួនឃើញឈាម ក៏ងងឹតមុខមើលលែងឃើញអ្វី បន្ទាប់ពីកាប់ខ្លួនរួចក៏ជិះម៉ូតូគេចខ្លួនបាត់អស់។ ពួកគេមានកាំបិតចំនួន ៣ដើម ក្នុងនោះជ្រូកកាន់កាំបិតតាំងតោ ចំនួន ១ដើម និងបក្សពួកកាន់កាំបិតវែងចំនួន ២ដើមទៀត។ ពេលពួកវាកាប់នោះ ខ្លួនបានរបួសត្រង់ដើមដៃស្តាំ ០១កាំបិត ត្រូវកែងដៃឆ្វេង ០១កាំបិត ដើមដោះខាងឆ្វេង ០១កាំបិត និងកដៃឆ្វេង ០១កាំបិត មុតដាច់ដល់ឆ្អឹង។ ខ្លួនព្យាបាលរបួសអស់ប្រាក់ ៤.០០០.០០០ (បួនលាន) រៀល សម្រាកនៅផ្ទះ ៣ ទៅ ៤ខែ។ ក្រៅពីខ្លួន មិត្តភក្តិកូនប្រុសខ្លួន បានរងរបួសត្រង់ខ្នងចំនួន ០២ កាំបិត។ ខ្លួនសុំទាមទារសំណងសម្រាប់ព្យាបាលរបួស និងទារសំណងជំងឺចិត្តការខាតបង់ពេលវេលា និងសោហ៊ុយផ្សេងៗសរុប ១៤.០០០.០០០ (ដប់បួនលាន) រៀល។

- សាក្សីឈ្មោះ [redacted] សីលា ភេទប្រុស បានឆ្លើយថា នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ខ្លួនបបួលឈ្មោះ សារ៉ាយ ជិះម៉ូតូទៅលេងនៅកន្លែងកើតហេតុ ហើយបានជួបឈ្មោះ អន, ឈ្មោះ ជ្រូក និងគ្នាវាបួននាក់ទៀតនៅទីនោះ ពេលនោះឈ្មោះ អន គេក៏ដើរមករករឿងខ្លួន ហើយនិយាយថា អញចង់កាប់ហែងនៅសំណង់ រួចក៏នាំគ្នាជិះម៉ូតូចេញបាត់ទៅ។ ខ្លួនក៏តេហៅឪពុកឱ្យមកកន្លែងកើតហេតុ។ ពេលនោះឪពុកខ្លួនទៅសួរនាំឈ្មោះ អន ចំណែកអ្នកផ្សេងទៀត នៅអង្គុយលើម៉ូតូ និងឈរក្បែរម៉ូតូនៅចម្ងាយប្រហែល ០៣ម៉ែត្រ ថាហេតុអីចង់កាប់កូនពូ ពេលនោះដោយដឹងថា រូបខ្លួនត្រូវគេចង់កាប់ ខ្លួនក៏ដើរចុះទៅសំណង់ទឹក ចំណែកឈ្មោះ ជ្រូក និងគ្នារបស់វាផ្សេងទៀតនៅកន្លែងម៉ូតូ លុះពេលលឺសូរភ្លូស ខ្លួនបែរមកមើល ក៏ឃើញឈ្មោះ ជ្រូក កាន់កាំបិតតាំងតោរត់ទៅកាប់ត្រូវដៃឪពុករបស់ខ្លួន រួចរត់ឡើងម៉ូតូ ភ្លាមនោះគ្នារបស់វាក៏រត់ឡើងម៉ូតូព្រមគ្នាដែរ ពេលនោះខ្លួនក៏រត់ឡើងមកវិញ ហើយក៏ឃើញឪពុករបស់ខ្លួនត្រូវពួកវាកាប់ត្រូវដៃទាំងសងខាង និងកាប់ត្រូវខ្លួនប្រាណគាត់ផងដែរ។

- តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អុល ភេទប្រុស បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅពេលកើតហេតុខ្លួនពុំបានឃើញផ្ទាល់ទេ ក្រោយកើតហេតុខ្លួនលឺគេប្រាប់ថា ឈ្មោះ ជ្រូក និងបក្សពួកប្រាំនាក់ទៀត បានកាប់កូនប្រុសខ្លួនឈ្មោះ [redacted] សារ៉ាយ បណ្តាលឱ្យរងរបួស ០២កន្លែង របួសត្រង់ចង្កេះប្រវែង ០១តឹក ជម្រៅជិតដល់ពោះវៀន និងរបួសស្លាបប្រចៀវខាងឆ្វេង ប្រវែង ០១តឹក រួចហើយខ្លួនក៏បញ្ជូនកូនទៅព្យាបាលរបួសនៅឯមន្ទីរពេទ្យស្រុកមង្គលបូរី។ ក្នុងរឿងនេះខ្លួនសុំទាមទារសំណងសម្រាប់ព្យាបាលរបួសចំនួន ២.០០០.០០០ (ពីរលាន) រៀល និងសុំសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសោហ៊ុយផ្សេងៗចំនួន ១៣.០០០.០០០ (ដប់បីលាន) រៀល។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សារ៉ាយ ភេទប្រុស បានឆ្លើយថា កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ខ្លួន និងឈ្មោះ សីលា បានជិះម៉ូតូទៅលេងកញ្ចុះថៃវិន នៅភូមិដូនឡឹក ពេលទៅដល់ឃើញមនុស្សប្រុស០៦នាក់ នៅទីនោះ បន្ទាប់មកឈ្មោះ សីលា បានប្រកែកគ្នាជាមួយពួកនោះពីរឿងស្រី ម្ចាស់កញ្ចុះលឺក៏ដេញចេញ ពេលនោះពួកគេក៏ជិះម៉ូតូចេញបាត់ទៅ ឈ្មោះ សីលា បានទូរស័ព្ទប្រាប់ឪពុកវាថា គេចង់វាយវាមួយសន្ទុះឪពុកវាក៏មកដល់ ហើយទៅសួរនាំពួកនោះនៅកន្លែងសំណង់ ដោយឪពុករបស់ សីលា បានសួរថា មានរឿងអីបានចង់វាយកូនពូ ពេលនោះគ្នាវាម្នាក់មិនស្គាល់ឈ្មោះ ក៏ច្រានគាត់ ហើយគ្នាវាប្រាំនាក់ទៀត ដក

កាំបិតរត់ទៅកាប់លើគាត់ត្រូវជាច្រើនកន្លែង របួសធ្ងន់ធ្ងរ ហើយគ្នាវាម្នាក់យកមួកសុវត្ថិភាពមកវាយក្បាលខ្លួនពីក្រោយ ដួលទៅនឹងដី ពេលក្រោកឡើងវាយកមួកគប់ចំគុម្ពត្រចៀកខាងឆ្វេង ហើយអ្នកផ្សេងមកកាប់ខ្លួនពីក្រោយ ហើយក៏ជិះម៉ូតូគេចខ្លួនបាត់អស់ទៅ។

- តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថោង ហៅ ង៉ា ភេទប្រុស បានឆ្លើយថា កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោង ១២ថ្ងៃ ខ្លួនបានជិះម៉ូតូទៅលេងនៅសំណង់កាត់ស្ទឹង ស្ថិតនៅភូមិដូនឡឹក ឃុំសំបួរ ពេលទៅដល់ខ្លួនបានទៅអង្គុយលេងជាមួយស្រីៗនៅកញ្ចុះ ដល់ម៉ោង ០៣រសៀល ខ្លួនទៅលេងទឹកបានជួបឈ្មោះ ជ្រូក, ឈ្មោះ សីហា, ឈ្មោះ វ៉េ, ឈ្មោះ អន, និងឈ្មោះ ថៃ ឈ្មោះគ្នាជាមួយមនុស្សចាស់ម្នាក់ និងក្មេងៗពីរនាក់ពុំស្គាល់ បន្ទាប់មកឃើញបុរសចំណាស់ដកខ្សែក្រវ៉ាត់ពីចង្កេះវៃទៅលើឈ្មោះ អន ពេលនោះឈ្មោះ សីហា និងឈ្មោះ អន បានទាញកាំបិតពីម៉ូតូកាប់ទៅលើបុរសចំណាស់ និងក្មេងពីរនាក់នោះ តែពុំបានដឹងថាត្រូវកន្លែងណាខ្លះទេ។ ចំណែកឈ្មោះ ជ្រូក, ឈ្មោះ ថៃ និងឈ្មោះ វ៉េ អង្គុយនៅលើម៉ូតូ ពុំបានធ្វើសកម្មភាពវាយ និងកាប់ទៅលើបុរសចំណាស់ និងក្មេងពីរនាក់នោះទេ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានថា កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ពិតជាមានអំពើហិង្សាប្រព្រឹត្តដោយជនជាប់ចោទទាំង ០៦នាក់ នោះមែន ដែលដើមហេតុដំបូងឈ្មោះ សីលា បានមានទំនាស់ជាមួយឈ្មោះ អន ហើយក៏តេហៅឪពុកឱ្យមកសួរនាំ ពេលឈ្មោះ ហៀ ទៅសួរនាំឈ្មោះ អន ក៏ត្រូវជនទាំងប្រាំមួយនាក់ស្ទុះមកវាយ និងកាប់ព្រមគ្នាតែម្តង។ ចំពោះចម្លើយរបស់ឈ្មោះ [redacted] ថុង បានឆ្លើយនៅដំណាក់កាលស៊ើបសួរថា ខ្លួននៅចំងាយ ៨ ម៉ែត្រ ជាចម្លើយដោះសារ ព្រោះដំលោះមានគ្នាតែ ៦នាក់ ដោយ ៥នាក់នៅក្បែរម៉ូតូ ម៉្យាងចម្លើយដោះសារនេះមិនមានភស្តុតាងដោះបន្ទុកទេ។ អំពើរបស់ជនទាំងប្រាំមួយនាក់ គឺជាអំពើកាចសាហាវ ស្នើសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទទាំង ៦នាក់ ក្នុងកម្រិតអតិបរិមា សុំទាមទារសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលរបួសកូនក្តីខ្លួនឈ្មោះ [redacted] ហៀ ចំនួន ដប់បួនលានរៀល និងឈ្មោះ [redacted] អុល ចំនួន ដប់បីលានរៀល និងស្នើសុំឱ្យតុលាការចេញដីកាចាប់ខ្លួនជនទាំងនោះមកផ្តន្ទាទោសតាមច្បាប់។

- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន បន្ទាប់ពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ ឃើញថាដំបូងកូនប្រុសរបស់ជនរងគ្រោះ មានជំលោះជាមួយឈ្មោះ អន ហើយក៏បានទូរស័ព្ទហៅឪពុកដែលជាជនរងគ្រោះឱ្យមក បន្ទាប់មកពេលជនរងគ្រោះសួរនាំឈ្មោះ អន ហើយបានយកដៃទៅដាក់លើស្មារ ពេលនោះឈ្មោះ អន ក៏ច្រានជនរងគ្រោះចេញ ភ្លាមនោះបក្សពួករបស់ឈ្មោះ អន ដែលខ្លះឈរ ខ្លះអង្គុយលើម៉ូតូ ស្ថិតនៅចម្ងាយបីម៉ែត្រ ក៏ដកកាំបិតពីម៉ូតូរត់ទៅកាប់លើជនរងគ្រោះព្រមគ្នា ពេលនោះជនរងគ្រោះបានឃើញអ្នកមានកាំបិតចំនួន ០៣នាក់ មានឈ្មោះ ជ្រូក និងពីរនាក់ទៀតមិនស្គាល់ឈ្មោះ។ តាមចម្លើយជនរងគ្រោះ និងចម្លើយសាក្សី បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ហៅ អន, ឈ្មោះ [redacted] សុនិន ហៅ ជ្រូក, ឈ្មោះ [redacted] ថៃ, ឈ្មោះ [redacted] វ៉េ, ឈ្មោះ [redacted] សីហា ហៅ ហា និងឈ្មោះ [redacted] ថុង ហៅ ង៉ា ពិតជាបានប្រព្រឹត្តអំពើហិង្សា ដោយយកកាំបិតតាំងតោ និងដាវ កាប់ទៅលើជនរងគ្រោះឈ្មោះ ហាច ហៀ និងឈ្មោះ [redacted] សារ៉ាយ បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ពិតប្រាកដមែន កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទ សំដែងឱ្យឃើញពីចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះ។ តំណាងអយ្យការ សុំរក្សាបទចោទប្រកាន់ដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថុង ធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានពិនិត្យឯកសារ និងស្តាប់ការសួរដេញដោលនាពេលសវនាការ នៅថ្ងៃកើតហេតុកូនក្តីខ្លួន ពិតជា

មានវត្តមាននៅកន្លែងកើតហេតុនោះមែន តែកូនក្ដីខ្លួនពុំបានប្រព្រឹត្តទេ ហើយក៏គ្មានភស្តុតាង ឬសាក្សីណាបញ្ជាក់ថាកូនក្ដីខ្លួនបានប្រព្រឹត្តដែរ។ ដំបូងអ្នកឈ្លោះ គឺឈ្មោះ អន និងឈ្មោះ សីលា បន្ទាប់មកពេលមានរឿងរហូតឈានដល់កាប់គ្នា អ្នកដែលកាប់ទៅលើជនរងគ្រោះ គឺម្នាក់ឈ្មោះ ជ្រូក។ យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ថុង ហៅ ង៉ា សំណូមពរតុលាការ សុំឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទ។

- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ និងស្ដាប់អំណានចម្លើយសាក្សី បញ្ជាក់បានថា កូនក្ដីខ្លួនពិតជាបានឈ្លោះគ្នាពិតប្រាកដមែន ដោយមូលហេតុមានទំនាស់នឹងកូនរបស់ឈ្មោះ [redacted] ហៀ តែកូនក្ដីខ្លួនមិនមានបំណងវាយទេ តែដោយសារឈ្មោះ [redacted] បានរុញ និងដកខ្សែក្រវ៉ាត់មុន ហើយគ្នាខ្លួនមានឈ្មោះ ជ្រូក និងពីរនាក់មិនស្គាល់ បានយកកាំបិតមកកាប់តែម្ដង ចំណែកកូនក្ដីខ្លួនគ្រាន់តែបានឈ្លោះគ្នាជាមួយជនរងគ្រោះ តែមិនបានកាប់ទេ មូលហេតុមកពីជនរងគ្រោះ។ ដូច្នេះក្នុងនាមជាមេធាវី សំណូមពរតុលាការពិចារណាផ្ដល់ស្ថានសម្រាលដល់កូនក្ដីរបស់ខ្លួន។

- លោក [redacted] ធ្វើសេចក្ដីសន្និដ្ឋានបន្ថែមថា នៅថ្ងៃកើតហេតុបក្សពួកឈ្មោះ អន មានតែប្រាំមួយនាក់ទេ ពុំមានអ្នកផ្សេងទៀតទេ ពេលឈ្មោះ ហៀ ទៅសួរនាំឈ្មោះ អន និងយកដៃកាន់ស្មារ ហើយត្រូវឈ្មោះ អន រុញចេញវិញ ភ្លាមនោះបក្សពួកឈ្មោះ អន ក៏ស្ទុះមកកាប់ ទើបកូនក្ដីខ្លួនដកខ្សែក្រវ៉ាត់ ហើយក៏ត្រូវជនទាំងនោះព្រួតគ្នាកាប់ និងវាយលើកូនក្ដីខ្លួនតែម្ដង។

## តុលាការ

- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយ និងអំណានដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់ចម្លើយសាក្សី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានានៅក្នុងសំណុំរឿង

## ៣. សំអាងហេតុ

១. តាមដីកាដំណោះស្រាយលេខ ៥០៦៧ ពស.ព្រស"ក"/២០ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បានសម្រេចបញ្ជូនជនជាប់ចោទៈ

- ឈ្មោះ [redacted] វិចិត្រ ហៅ អន ភេទប្រុស អាយុ ១៧ឆ្នាំ។
- ឈ្មោះ [redacted] សុនិន ហៅ ជ្រូក ភេទប្រុស អាយុ ១៩ឆ្នាំ។
- ឈ្មោះ [redacted] ថៃ ភេទប្រុស អាយុ ១៩ឆ្នាំ។
- ឈ្មោះ [redacted] វ៉ៃ ភេទប្រុស អាយុ ១៩ឆ្នាំ។
- ឈ្មោះ [redacted] សីហា ហៅ ហា ភេទប្រុស អាយុ ១៩ឆ្នាំ។
- ឈ្មោះ [redacted] ថោង ហៅ ង៉ា ភេទប្រុស អាយុ ២១ឆ្នាំ។



Scanned with CamScanner

បញ្ជូនមកជំនុំជម្រះ *ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាសហចារី)* ប្រព្រឹត្តនៅចំណុចសំណង់កាត់ស្ទឹង ស្ថិតនៅភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ។

២. តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀ ភេទប្រុស បានឆ្លើយថា នៅថ្ងៃកើតហេតុពេលខ្លួនជិះម៉ូតូទៅដល់កន្លែងកើតហេតុ បានជួបពួកគេមានគ្នា ០៦នាក់ ចំណោមនោះខ្លួនស្គាល់ឈ្មោះហៅក្រៅពីរនាក់ គឺឈ្មោះ អន និងឈ្មោះ ជ្រូក បន្ទាប់មកខ្លួនបានដើរទៅឈរនិយាយទល់មុខគ្នានឹងឈ្មោះ អន បក្សពួកវា ០៥នាក់ ខ្លះអង្គុយលើម៉ូតូ ខ្លះឈរក្បែរម៉ូតូ នៅចម្ងាយបីម៉ែត្រ នៅពេលនោះខ្លួនសួរថា ម៉េចបានរកកាប់កូនពូ និងយកដៃស្ដាំទៅកាន់ស្មារឈ្មោះ អន ហើយវាក៏ច្រានខ្លួនចេញ ខ្លួនក៏រុញទៅវាវិញ ពេលនោះខ្លួនបានឃើញឈ្មោះ ជ្រូក ដកកាំបិតតាំងតោចេញពីម៉ូតូ ខ្លួនក៏ចាប់ដកខ្សែក្រវ៉ាត់មកកាន់នៅដៃ ស្រាប់តែឈ្មោះជ្រូក និងក្មេងប្រុសពាក់អាវដៃវែង ពណ៌ខៀវ និងគ្នាវាម្នាក់ទៀត មានកាន់ដាវម្នាក់មួយ រត់មកកាប់ខ្លួនព្រមគ្នាពេលពួកវាកាប់ខ្លួនត្រូវមួយកាំបិត ខ្លួនឃើញឈាម ក៏ងងឹតមុខមើលលែងឃើញអ្វី បន្ទាប់ពីកាប់ខ្លួនរួចក៏ជិះម៉ូតូគេចខ្លួនបាត់អស់។ ខ្លួនរងរបួសត្រង់ដើមដៃស្ដាំ ០១កាំបិត ត្រង់កែងដៃឆ្វេង ០១កាំបិត ដើមដោះខាងឆ្វេង ០២កាំបិត និងកដៃឆ្វេង ០១កាំបិត។

៣. តាមអំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អុល បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅពេលកើតហេតុខ្លួនពុំបានឃើញផ្ទាល់ទេ ក្រោយកើតហេតុខ្លួនលឺគេប្រាប់ថា ឈ្មោះ ជ្រូក និងបក្សពួកប្រាំនាក់ទៀត បានកាប់កូនប្រុសខ្លួនឈ្មោះ [redacted] សារ៉ាយ បណ្ដាលឱ្យរងរបួស ០២កន្លែង របួសត្រង់ចង្កេះប្រវែង ០១តឹក ជម្រៅជិតដល់ពោះវៀន និងរបួសស្លាបប្រចៀវខាងឆ្វេង ប្រវែង ០១តឹក រួចហើយខ្លួនក៏បញ្ជូនកូនទៅព្យាបាលរបួសនៅឯមន្ទីរពេទ្យស្រុកមង្គលបូរី។

៤. តាមចម្លើយសាក្សីឈ្មោះ [redacted] សីលា និងឈ្មោះ [redacted] សារ៉ាយ បានឆ្លើយស្រដៀងគ្នាថា នៅថ្ងៃកើតហេតុ ពួកខ្លួនជិះម៉ូតូទៅលេងនៅកន្លែងកើតហេតុ បានជួបឈ្មោះ អន និងបក្សពួក ០៥នាក់ បន្ទាប់មកខ្លួន និងឈ្មោះ អន ក៏បានឈ្លោះប្រកែកគ្នាបន្តិចបន្តួច ហើយឈ្មោះ អន បាននិយាយថា អញចាំកាប់ហែងនៅសំណង់ រួចគេក៏នាំគ្នាជិះម៉ូតូចេញទៅបាត់ លឺអញ្ចឹងឈ្មោះ [redacted] សីលា ក៏តេហៅឪពុកឱ្យមកកន្លែងកើតហេតុ។ ពេលឪពុករបស់ឈ្មោះ [redacted] សីលា ឈរនិយាយគ្នាទល់មុខជាមួយឈ្មោះ អន រួចបានច្រានគ្នាទៅវិញទៅមក ស្រាប់តែឈ្មោះ ជ្រូក និងបក្សពួក រត់មកកាប់ឪពុករបស់ខ្លួនតែម្ដង។ ក្នុងចំណោមពួកគេទាំង ០៦នាក់ ឈ្មោះ ជ្រូក កាន់កាំបិតតាំងតោ ពីរនាក់ទៀតកាន់ដាវ ចំណែកអ្នកផ្សេងទៀតពុំមានកាំបិតទេ។

៥. តាមរបាយការណ៍លេខ ២៣១ នបស.មរ របស់អធិការដ្ឋាននគរបាលស្រុកមង្គលបូរី ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ បានធ្វើសេចក្ដីសន្និដ្ឋានបញ្ជាក់ថា ជនសង្ស័យទាំង ៦នាក់ មានឈ្មោះ ១.[redacted] វិចិត្រ ហៅ អន ភេទប្រុស, ២.ឈ្មោះ [redacted] សុនិន ហៅ ជ្រូក ភេទប្រុស, ៣. ឈ្មោះ [redacted] ថៃ ភេទប្រុស, ៤. ឈ្មោះ [redacted] វ៉ៃ ភេទប្រុស, ៥.ឈ្មោះ [redacted] វេហា ភេទប្រុស និងឈ្មោះ [redacted] ថុង ហៅ ង៉ា ភេទប្រុស ពិតជាមានការពាក់ព័ន្ធក្នុងករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ៣០ នាទី នៅចំនុចសំណង់កាត់ស្ទឹង ភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ប្រាកដមែន។

៦. យោងតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ចម្លើយរបស់សាក្សី, ចម្លើយរបស់ជនជាប់ចោទ, របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានានៅក្នុងសំណុំរឿង បញ្ជាក់បានថា នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ៣០ នាទី នៅចំណុចសំណាង់កាត់ស្ទឹង ស្ថិតនៅភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ពិតជាមានអំពើហិង្សាដែលបង្កឡើងដោយក្រុមរបស់ជនជាប់ចោទមានគ្នាចំនួន ៦នាក់ ក្នុងនោះមានជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ហៅ អន ភេទប្រុស, ឈ្មោះ [redacted] សុនិន ហៅ ជ្រូក ភេទប្រុស និងម្នាក់ទៀតមិនស្គាល់ បានកាប់ទៅលើជនរងគ្រោះបណ្ដាលឱ្យជនរងគ្រោះ ឈ្មោះ [redacted] ហៀ រងរបួសត្រង់ ដើមដៃស្ដាំ ០១កាំបិត ត្រង់កែងដៃឆ្វេង ០១កាំបិត ដើមដោះខាងឆ្វេង ០២កាំបិត និងកដៃឆ្វេង ០១កាំបិត ចំណែកជនរងគ្រោះឈ្មោះ [redacted] សារ៉ាយ បានរងរបួសចំនួន ពីរកន្លែងនៅត្រង់ ចង្កេះដោយមានស្នាមកាំបិតកាប់ត្រូវមានប្រវែងមួយតឹក ជម្រៅជិតដល់ពោះវៀន និងនៅស្លាបត្រចៀកខាងឆ្វេង មានប្រវែងមួយតឹក ប្រាកដមែន។

៧. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ហៅ អន ភេទប្រុស និងឈ្មោះ [redacted] សុនិន ហៅ ជ្រូក ភេទប្រុស ពិតបានយកកាំបិតកាប់លើជនរងគ្រោះឈ្មោះ [redacted] ហៀ និងឈ្មោះ [redacted] សារ៉ាយ ពិតប្រាកដមែន។ អំពើរបស់ជនជាប់ចោទ ស្ដែងឱ្យឃើញអំពី **ចេតនាទុច្ចរិត ពិតប្រាកដ** របស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើសដែលត្រូវបានចោទប្រកាន់។

៨. ជនជាប់ចោទស្ថិតនៅក្នុងវ័យដែលតុលាការអាចធ្វើការប្រកាសទោសព្រហ្មទណ្ឌបាន ហើយមិនមានសញ្ញាណណាមួយបញ្ជាក់បានថា ជនជាប់ចោទមានវិបត្តិខាងបញ្ញាស្មារតីឡើយ។

៩. តាមសំអាងហេតុខាងលើ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ហៅ អន ភេទប្រុស និងឈ្មោះ [redacted] សុនិន ហៅ ជ្រូក ភេទប្រុស ពីបទៈ ***ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាសហចារី)*** ប្រព្រឹត្តនៅចំណុចសំណាង់កាត់ស្ទឹង ស្ថិតនៅភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការប្រកាសពី ពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០. តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀ, ឈ្មោះ [redacted] សារ៉ាយ និងសាក្សីឈ្មោះ [redacted] សីលា បានឆ្លើយថា ជនជាប់ចោទមានគ្នា ៦នាក់ ប៉ុន្តែក្នុងចំណោមនោះមានជនជាប់ចោទ ៣នាក់ កាន់កាំបិតចំនួន ៣ដើម ដោយក្នុងនោះឈ្មោះ ជ្រូក កាន់កាំបិតតាំងតោ, ឈ្មោះ អន កាន់កាំបិតវែង និងម្នាក់ទៀត កាន់កាំបិតវែង ក្នុងម្នាក់ ១ ដើម មកកាប់ជនរងគ្រោះបណ្ដាលឱ្យរងរបួស ប៉ុន្តែមិនមានចម្លើយណាមួយបញ្ជាក់ថា ជនជាប់ចោទចំនួន ៣ នាក់ផ្សេងទៀតបានប្រើប្រាស់អំពើហិង្សាទៅលើជនរងគ្រោះឡើយ ដូច្នេះផ្អែកលើគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ *"មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ"* ដូច្នេះអំពើប្រព្រឹត្តខាងលើ មិនមានភស្តុតាងបញ្ជាក់ថាក្រៅពីឈ្មោះ អន, ឈ្មោះ ជ្រូក និងម្នាក់ទៀត បានប្រើប្រាស់អំពើហិង្សាទៅលើជនរងគ្រោះឡើយ។ ម្យ៉ាងវិញទៀត នៅក្នុងចំណោមអ្នកកាន់កាំបិតម្នាក់ ក្នុងចំណោម ៣នាក់ ដែលភាគីបានអះអាង ក៏បានបញ្ជាក់ដែលថា ខ្លួនមិនបានស្គាល់ឈ្មោះរបស់ជននេះឡើយ គឺស្គាល់តែឈ្មោះ អន និងឈ្មោះ ជ្រូក តែប៉ុណ្ណោះដែលបានកាប់មកលើខ្លួន។ ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ជនរងគ្រោះ, សាក្សី និងភស្តុតាងនានា



Scanned with CamScanner

នៅក្នុងសំណុំរឿង នៅតែមិនអាចកំណត់ពីអត្តសញ្ញាណអ្នកប្រព្រឹត្តឱ្យបានច្បាស់លាស់ ដូច្នេះវិមតិសង្ស័យបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច យោងតាមបញ្ញត្តិមាត្រា ៣៥១ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១១. ផ្អែកតាមសំអាងហេតុចំនុច ១០ ខាងលើ មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] ថោង ហៅ ង៉ា, ឈ្មោះ [redacted] ថៃ, ឈ្មោះ [redacted] វ័យ និងឈ្មោះ [redacted] សីហា ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាសហចារី) ប្រព្រឹត្តនៅចំណុចសំណង់កាត់ស្ទីង ស្ថិតក្នុងភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការឱ្យជនជាប់ចោទរួចខ្លួនពីបទចោទ តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១២. មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួសកូនក្តីខ្លួនឈ្មោះ [redacted] ហៀ ចំនួនដប់បួនលានរៀល និងឈ្មោះ [redacted] អុល ចំនួន ដប់បីលានរៀល។ គប្បីតុលាការលើកមកពិចារណា។

១៣. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន រក្សាបទចោទប្រកាន់ដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ គប្បីតុលាការលើកមកពិចារណា។

១៤. លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យតុលាការពិចារណាផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន។ គប្បីតុលាការលើកមកពិចារណា។

១៥. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថោង បានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យតុលាការ សម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។ គប្បីតុលាការលើកមកពិចារណា។

១៦. ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ហៅ អន និងឈ្មោះ [redacted] សុនិន ហៅ ជ្រូក បានប្រព្រឹត្តបទមជ្ឈិម និងបានអវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធី គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៧. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហាច ហៀ សុំទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួស ចំនួន ១៤.០០០.០០០ (ដប់បួនលាន) រៀល និងឈ្មោះ [redacted] អុល សុំទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួស ចំនួន ១៣.០០០.០០០ (ដប់បីលាន) រៀល។ គប្បីតុលាការលើកមកពិចារណា។

## ៤. ហេតុដូច្នេះ សម្រេច

**១. ឱ្យជនជាប់ចោទ**

**១.១.** ឈ្មោះ [redacted] **ថៃ** ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូមិ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ធី "រស់" ម្តាយឈ្មោះ [redacted] សារី "រស់" នៅលីវ ជានីតិជនកម្រិតវប្បធម៌ថ្នាក់ទី៩ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**១.២.** ឈ្មោះ [redacted] **ច័យ** ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋាននៅភូ [redacted]



Scanned with CamScanner

[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] សារ៉េត "រស់" ម្ដាយឈ្មោះ [redacted] សារ៉ែន "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**១.៣.** ឈ្មោះ [redacted] **សីហា** ហៅ **ហា** ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋាននៅភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ភារម្យ "រស់" ម្ដាយឈ្មោះ [redacted] រ៉ា "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៩ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**១.៤.** ឈ្មោះ [redacted] **ថោង** ហៅ **ថ៉ា** ភេទប្រុស អាយុ ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្ននៅ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] រឿ "រស់" ម្ដាយឈ្មោះ [redacted] ធឿត "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៨ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

**រួចខ្លួន**ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ ក្នុងឋានៈជាសហចារី)** ប្រព្រឹត្តនៅចំណុចសំណង់កាត់ស្ទឹង ស្ថិតក្នុងភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ។

២. **ផ្ដន្ទាទោស៖**

**២.១.** ឈ្មោះ [redacted] **ចិចិត្រ** ហៅ **អន** ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីកន្លែងកំណើតភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូមិ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] អាត់ "រស់" ម្ដាយឈ្មោះ [redacted] ស៊ុន "រស់" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**កំណត់ដាក់ពន្ធនាគាររយៈពេល ០១ (មួយ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ ក្នុងឋានៈជាសហចារី)** ប្រព្រឹត្តនៅចំណុចសំណង់កាត់ស្ទឹង ស្ថិតក្នុងភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

**២.២.** ឈ្មោះ [redacted] **សុនិន** ហៅ **ជ្រូក** ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] រេន "រស់" ម្ដាយឈ្មោះ [redacted] សេង "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៧ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**កំណត់ដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ដោយប្រើអាវុធ និងដោយមានមនុស្សច្រើននាក់ ក្នុងឋានៈជាសហចារី)** ប្រព្រឹត្តនៅចំណុចសំណង់កាត់ស្ទឹង ស្ថិតក្នុងភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ។៚



Scanned with CamScanner

៣. បង្គាប់ឱ្យឈ្មោះ [redacted] **វិចិត្រ** ហៅ **អន** និងឈ្មោះ [redacted] **សុនិន** ហៅ **ជ្រូក** (មានអត្តសញ្ញាណខាងលើ) សងសំណងចំនួន ១៤.០០០.០០០ (ដប់បួនលាន) រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ហាច ហៀ** និងសងសំណងចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ចេង អុល**។ ច្រានចោលការទាមទារលើសពីនេះ។

**៤. ដីកាបង្គាប់ឱ្យចាប់ខ្លួន**

៤.១. បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សីហា ភេទប្រុស និងឈ្មោះ [redacted] វ័យ ភេទប្រុស *(អត្តសញ្ញាណដូចខាងលើ)*។

៤.២. បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] វិចិត្រ ហៅ អន និងឈ្មោះ [redacted] សុនិន ហៅ ជ្រូក *(អត្តសញ្ញាណដូចខាងលើ)*។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហៀ**, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **វិចិត្រ**, ឈ្មោះ [redacted] **សុនិន**, ឈ្មោះ [redacted] **ជ័យ**, ឈ្មោះ [redacted] **ថៃ**, ឈ្មោះ [redacted] **សីហា**, ឈ្មោះ [redacted] **ថោង**, និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អុល** ។

*ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។៚*

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
បន្ទាយមានជ័យ, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១
**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**បន្ទាយមានជ័យ**.ថ្ងៃទី ១៧ ខែ ... ឆ្នាំ២០២១
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner